## ការសម្លាប់រង្គាល (extermination)

ការសម្លាប់រង្គាល ជាបទល្មើសនៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crime against humanity)។ វាជាសកម្មភាពមួយ ឬច្រើន ដែលនាំឲ្យមានការស្លាប់មនុស្សច្រើននាក់ ដោយផ្ទាល់ ឬប្រយោល តាមរយៈការចូលរួមក្នុងការរៀបចំការសម្លាប់មនុស្សទ្រង់ទ្រាយធំ (Kayishema ICTR-95-1-T, 21 May 1999, S. 146)។

សកម្មភាពសម្លាប់រង្គាល មានលក្ខណៈរួម (collective nature)។ ខុសពីអំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល មិនទាមទារចេតនាពិសេស (specific intent) បំផ្លាញពូជសាសន៍ទេ។

សម្រាប់ធាតុអត្តនោម័តនៃបទល្មើសនេះ ជនល្មើស មានបំណងសម្លាប់មនុស្សច្រើននាក់ ឬបង្ករបួសស្នាមធ្ងន់ធ្ងរ ជាមួយការដឹងដោយសមស្របថា ទង្វើ (act) ឬការខកខាន (omission) នោះនឹងទំនងនាំឲ្យមានការស្លាប់។ ក្នុងន័យនេះ ការធ្វេសប្រហែសធ្ងន់ធ្ងរ (gross negligence) ឬ ខ្ជីខ្ជា (recklessness) មិនគ្រប់គ្រាន់ទេ។ មូលហេតុ (motive) នៃការសម្លាប់ ក៏មិនមែនជាផ្នែកមួយ ដែលទាមទារ ក្នុងធាតុផ្សំអត្តនោម័តនៃបទល្មើសនេះដែរ។ ដូចគ្នានេះដែរ ធាតុផ្សំការរើសអើង (discrimination) ក៏មិនតម្រូវដែរ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, p. 320)។